អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះសាលាដំបូងកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២

នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២ ប្រឆាំង ខៀវ សំផន និង នួន ជា ដោយដកចេញនូវអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាដំណោះស្រាយ ហើយដែលមិនត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ អនុលោមតាមវិធាន ៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុង។

នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងសំណុំរឿង ០០២ ទៅជាសំណុំរឿងពីរ ឬច្រើន។ សេចក្តីសម្រេចនាពេលក្រោយមកទៀត របស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចបំបែកសំណុំរឿង ០០២/០១ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលសម្រេចតម្កល់នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣។ សេចក្តីសម្រេចបន្ថែមទៀតរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចបំបែកសំណុំរឿង ០០២/០២ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលសម្រេចតម្កល់ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។ នៅក្នុងសេចក្តីសម្រេចថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសផ្អាកបណ្តោះអាសន្នចំពោះបទចោទនានាដែលស្ថិតនៅក្រៅពីវិសាលភាពនៃសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ដោយរង់ចាំការសម្រេចសេចក្តីសមស្របរបស់អង្គជំនុំជម្រះសាលាដំបូង។ បទចោទប្រកាន់ប្រឆាំង ខៀវ សំផន និង នួន ជា ពាក់ព័ន្ធទៅនឹងអង្គហេតុនានានៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានជំនុំជម្រះរួចរាល់ជាស្ថាពរ ដោយអង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីកានៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦។ លើសពីនេះទៀត សវនាការពិនិត្យភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ បានបញ្ចប់នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧។

នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់ពីភាគីនានានៃសំណុំរឿង ០០២ អំពីស្ថានភាពនៃអង្គហេតុទាំងឡាយដែលមិនត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គហេតុនានាដែលបានយកមកជំនុំជម្រះ ឬដែលនឹងត្រូវយកមក

ជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ និង សំណុំរឿង ០០២/០២ គឺជាតំណាងសមស្របចំពោះវិសាលភាពនៃដីកាដំណោះស្រាយ និងបានឆ្លុះបញ្ចាំងដ៏សមស្របនៃអំពើឧក្រិដ្ឋ និងការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ទាំងមូល។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការបន្តដំណើរការជំនុំជម្រះលើសពីនេះបន្ថែមទៀតនៅក្នុងសំណុំរឿង ០០២ នឹងមិនផ្តល់ជាប្រយោជន៍ដល់ដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ មានអត្ថន័យ និងឆាប់រហ័សនោះទេ ដូច្នេះហើយ អង្គជំនុំជម្រះសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ហើយដែលមិនត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២។

បន្ទាប់ពីសេចក្តីសម្រេចនេះ នឹងមិនមានកិច្ចដំណើរការនីតិវិធីបន្ថែមទៀតទេនៅក្នុងសំណុំរឿង ០០២ ចំពោះការដ្ឋានស្រែអំបិល និង ការដ្ឋានព្រៃស, មន្ទីរសន្តិសុខ សង់ មន្ទីរសន្តិសុខ កោះខ្សង មន្ទីរសន្តិសុខ ព្រៃដំរីស្រុត មន្ទីរសន្តិសុខ វត្តគីរីរម្យ មន្ទីរសន្តិសុខ ភូមិភាគឧត្តរ មន្ទីរសន្តិសុខ វត្តធ្លក និង មន្ទីរសន្តិសុខ គោកក្តួច, កន្លែងសម្លាប់មនុស្សក្នុងស្រុក ១២ (ភូមិភាគបស្ចិម) ទួលពោធិជ្រៃ (អង្គជំនុំជម្រះកត់សម្គាល់ថា អង្គហេតុដែលទាក់ទងនឹងទីកន្លែងនេះត្រូវបានយកមកជំនុំជម្រះផ្នែកខ្លះក្នុងសំណុំរឿង ០០២/០១) និង កន្លែងសម្លាប់មនុស្សនៅស្ទឹងតូច, ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគបូព៌ា (ដំណាក់កាលទី៣), ការប្រព្រឹត្តលើពុទ្ធសាសនិក (ទូទាំងប្រទេស), ការប្រព្រឹត្តលើជនជាតិចាមនៅមន្ទីរសន្តិសុខ ក្រូចឆ្មា និង ឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាម។ ទោះបីជាយ៉ាងនេះក្តី ភ័ស្តុតាងដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវបានដកចេញ អាចត្រូវបានយោងក្នុងករណីដែលវិសាលភាពនៃអង្គហេតុទាំងនោះមានភាពពាក់ព័ន្ធទៅនឹងអង្គហេតុដែលមាននៅក្នុងសំណុំរឿង ០០២/០២។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖


លោកស្រី Hayat Abu Saleh
មន្ត្រីព័ត៌មានសាធារណៈ
ទូរសព្ទដៃលេខ៖ +855 (0) 12 488 936
ទូរសព្ទលើតុលេខ៖ +855 (0) 23 860 191
អ៊ីមែល៖ abusaleh@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +855 (0)12 488 156
ទូរសព្ទលើតុលេខ៖ +855 (0)23 861 564
អ៊ីមែល៖ neth.phektra@eccc.gov.kh